# ជំពូក F:
# សម្ភារៈសិក្សានានាសំរាប់ការប្រឡងលោកនិតិ (ប្រវត្តិសាស្ត្រនិងរដ្ឋាភិបាល)

**ចាប់ផ្តើមពីថ្ងៃទី 1 ខែតុលាឆ្នាំ 2008, ក្រសួងផ្តល់សេវាចូលសញ្ជាតិសហរដ្ឋអាមេរិកនិងអន្តោប្រវេសន៍ (USCIS) នឹងចាប់ផ្តើមប្រើមុខវិជ្ជាប្រឡងចូលសញ្ជាតិថ្មី។ តើមុខវិជ្ជាកែប្រែណាដែលអ្នកនឹងប្រឡង?**

| មុខវិជ្ជាប្រឡងបច្ចុប្បន្ន | អ្នកត្រូវតែជ្រើសរើស | មុខវិជ្ជាប្រឡងថ្មី |
|---|---|---|
| ការធ្វើសម្ភាសន៍របស់អ្នកគឺនៅមុនថ្ងៃទី 1 ខែតុលាឆ្នាំ 2008 | អ្នកដាក់ពាក្យសុំនៅមុនថ្ងៃទី 1 ខែតុលាឆ្នាំ 2008, *ប៉ុន្តែត្រូវធ្វើសម្ភាសន៍នៅចន្លោះពេលរវាង* ថ្ងៃទី 1 ខែតុលាឆ្នាំ 2008 និងថ្ងៃទី 1 ខែតុលាឆ្នាំ 2009 | អ្នកបានដាក់ពាក្យសុំក្រោយថ្ងៃទី 1 ខែតុលាឆ្នាំ 2008<br><br>អ្នកធ្វើសម្ភាសន៍គឺក្រោយថ្ងៃទី 1 ខែតុលាឆ្នាំ 2009 |

អ្នកនឹងត្រូវតែចេះអាន, សរសេរនិងនិយាយក្នុងការសន្ទនាភាសាអង់គ្លេស។ អ្នកក៏ត្រូវតែដឹងអំពីប្រវត្តិសាស្ត្រនិងរដ្ឋាភិបាលសហរដ្ឋអាមេរិក (ដែលហៅថា *លោកនិតិ*)។

ជំនាញការផ្នែកភាសាអង់គ្លេសរបស់អ្នកនឹងត្រូវធ្វើតេស្តតាមរបៀបដូចខាងក្រោមនេះ:

- ការអាន – អ្នកនឹងត្រូវបានគេស្នើឲ្យអានឃ្លាជាភាសាអង់គ្លេស។ អ្នកនឹងត្រូវគេផ្តល់លទ្ធភាពជូនបីដង។ អ្នកត្រូវតែមានចម្លើយត្រូវមួយ។
- ការសរសេរ – អ្នកនឹងត្រូវបានគេស្នើឲ្យសរសេរឃ្លាជាភាសាអង់គ្លេស។ អ្នកនឹងត្រូវគេផ្តល់លទ្ធភាពជូនបីដង។ អ្នកត្រូវតែមានចម្លើយត្រូវមួយ។
- ការនិយាយ – មន្ត្រីនៃ USCIS នឹងធ្វើតេស្តពីលទ្ធភាពការនិយាយភាសាអង់គ្លេសរបស់អ្នក នៅពេលអ្នកឆ្លើយសំណួរនានាអំពីខ្លួនអ្នកផ្ទាល់ នឹងពាក្យសុំចូលសញ្ជាតិរបស់អ្នកនៅឱកាសធ្វើសម្ភាសន៍របស់អ្នក។

អ្នកក៏នឹងត្រូវគេស្នើឲ្យឆ្លើយដោយផ្ទាល់មាត់ នូវសំណួរលោកនិតិមួយចំនួន ដើម្បីធ្វើតេស្តការយល់ដឹងពីប្រវត្តិសាស្ត្រនិងរដ្ឋាភិបាលសហរដ្ឋអាមេរិករបស់អ្នក។ គឺនឹងមានសំណួរ 10 ។ ដើម្បីប្រឡងជាប់ អ្នកត្រូវតែឆ្លើយត្រូវសំណួរចំនួនប្រាំមួយក្នុងចំណោមសំណួរទាំង 10 ។

បើអ្នកមានអាយុយ៉ាងតិច 65 ឆ្នាំ និងជាពលរដ្ឋរស់នៅជាអចិន្ត្រៃយ៍ដោយស្របច្បាប់ (ជនដែលមានប័ណ្ណបៃតង) សំរាប់យ៉ាងតិចចំនួន 20 ឆ្នាំ, អ្នកអាចសិក្សាចំនួនបន្ថយនៃសំណួរ។

នៅខាងក្រោមនេះគឺជាគំរូនៃសំណួរនានា ដែលអ្នកអាចត្រូវគេសួរនៅពេលការធ្វើសម្ភាសន៍ចូលសញ្ជាតិរបស់អ្នក។ សំណួរគំរូនានាសំរាប់មុខវិជ្ជាប្រឡងបច្ចុប្បន្ន គឺត្រូវបានចុះរាយផ្នែកដំបូង ដែលបន្តទៅទៀតដោយមានសំណួរគំរូនានាសំរាប់មុខវិជ្ជាប្រឡងថ្មី។

## សំនួរសិក្សានានាសំរាប់វិញ្ញាសារប្រឡងចូលសញ្ជាតិលេខបច្ចុប្បន្ន។

សំណួរខ្លះមានចម្លើយជាច្រើនដែលមានរាយជូន។ នេះគឺពីព្រោះ ប្រហែលជាមានរបៀបជាច្រើនក្នុងការនិយាយចំពោះវត្ថុតែមួយ ឬពីព្រោះគឺអាចមានចម្លើយច្រើនជាងមួយ។ អ្នកនឹងត្រូវតំរូវឲ្យឆ្លើយតែចម្លើយមួយមកពីចម្លើយរាយជូននេះ *លើកលែងតែសំណួរសួរដោយជាក់ច្បាស់សំរាប់ឲ្យ ឆ្លើយច្រើនជាងមួយ។* អ្នកនឹងត្រូវគេសួរ 10 សំណួរ និងត្រូវតែមានចម្លើយប្រាំមួយត្រូវក្នុងចំណោម 10 ។

| សំណួរ | ចម្លើយ |
|---|---|
| **AMERICAN GOVERNMENT QUESTIONS** | |
| សំណួរទាក់ទងនឹងរដ្ឋាភិបាល | |
| **Principles of American Democracy** | |
| គាលការណ៍នៃប្រជាធិបតេយ្យអាមេរិកាំង | |
| 1. What is the supreme law of the land? | The Constitution |
| 1. តើអ្វីជាច្បាប់កំពូលរបស់នគរ? | រដ្ឋធម្មនុញ្ញ |



**បានបង្កើតឡើងដោយ Seattle Public Library ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ King County Library System និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល**

**(City of Seattle New Citizen Initiative)**

| សំណួរ | ចម្លើយ |
|---|---|
| 2. What does the Constitution do? | Sets up the government; defines the government; protects basic rights of Americans |
| 2. តើរដ្ឋធម្មនុញ្ញធ្វើអ្វីខ្លះ? | រៀបចំរដ្ឋាបាល; កំណត់អត្ថន័យឲ្យរដ្ឋាបាល; ការពារមូលដ្ឋានច្បាប់នៃជនអាមេរិកាំងទាំងអស់ |
| 3. The idea of self-government is in the first three words of the Constitution. What are these words? | "We the People" |
| 3. មតិនៃរដ្ឋាភិបាលខ្លួនឯងគឺនៅក្នុងពាក្យបីម៉ាត់នៃរដ្ឋធម្មនុញ្ញ។ តើពាក្យទាំងនេះមានអ្វីខ្លះ? | "We the People" ("យើងជាប្រជាជន") |
| 4. What is an amendment? | A change (to the Constitution); an addition (to the Constitution) |
| 4. អ្វីហៅថាវិសោធនកម្ម? | ការកែប្រែ (ចំពោះរដ្ឋធម្មនុញ្ញ); ការបន្ថែម (ចំពោះរដ្ឋធម្មនុញ្ញ) |
| 5. What do we call the first 10 amendments to the Constitution? | The Bill of Rights |
| 5. តើយើងហៅវិសោធនកម្មនៃរដ្ឋធម្មនុញ្ញដំបូងទាំង 10 ដូចម្តេច? | សេចក្តីប្រកាសសិទ្ធិឯកត្តជន |
| 6. What is <u>one</u> right or freedom from the First Amendment? | Speech; religion; assembly; press; petition the government |
| 6. តើសិទ្ធិឬសេរីភាព<u>មួយ</u>មកពីវិសោធនកម្មហៅអ្វី? | ការនិយាយ; សាសនា; ការប្រជុំ; ការផ្សាយព័ត៌មាន; ការប្តឹងទាមទារដល់រដ្ឋាភិបាល |
| 7. How many amendments does the Constitution have? | Twenty-seven (27) |
| 7. តើវិសោធនកម្មនៅក្នុងរដ្ឋធម្មនុញ្ញមានចំនួនប៉ុន្មាន? | ម្ភៃប្រាំពីរ (27) |
| 8. What did the Declaration of Independence do? | Announced our independence (from Great Britain); declared our independence (from Great Britain); said that the United States is free (from Great Britain) |
| 8. តើសេចក្តីប្រកាសនៃឯករាជ្យ បានធ្វើអ្វីខ្លះ? | ថ្លែងឲ្យដឹងឯករាជ្យរបស់យើង (ពីចក្រភពអង់គ្លេស); ប្រកាសឯករាជ្យរបស់យើង (ពីចក្រភពអង់គ្លេស); និយាយដូច្នេះ សហរដ្ឋអាមេរិកគឺមានសេរីភាព (ពីចក្រភពអង់គ្លេស) |
| 9. What are <u>two</u> rights in the Declaration of Independence? | Life; liberty; pursuit of happiness |
| 9. តើសិទ្ធិ<u>ពីរ</u>នៅក្នុងការប្រកាសឯករាជ្យគឺជាអ្វី? | ជីវិត; សេរីភាព; ការស្វែងរកសេចក្តីសប្បាយ |
| 10. What is freedom of religion? | You can practice any religion, or not practice a religion |
| 10. តើអ្វីជាសេរីភាពសាសនា? | អ្នកអាចជឿសាសនាណាមួយ ឬមិនជឿសាសនាណាក៏បាន |
| 11. What is the economic system in the United States? | Capitalist economy; market economy |
| 11. តើប្រព័ន្ធសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកជាអ្វី? | សេដ្ឋកិច្ចមូលធន; សេដ្ឋកិច្ចទីផ្សារ |
| 12. What is the "rule of law"? | Everyone must follow the law; leaders must obey the law; government must obey the law; no one is above the law. |
| 12. អ្វីទៅហៅថា "វិធាននៃច្បាប់"? | ម្នាក់ៗត្រូវអនុវត្តតាមច្បាប់; អ្នកដឹកនាំទាំងអស់ត្រូវគោរពច្បាប់; រដ្ឋាភិបាលត្រូវគោរពច្បាប់; គ្មានជនណាម្នាក់នៅលើច្បាប់ឡើយ។ |
| **System of Government** | |
| **ប្រព័ន្ធរដ្ឋាភិបាល** | |
| 13. Name <u>one</u> branch or part of the government. | Legislative (Congress); executive (President); judicial (the courts) |
| 13. ចូរឲ្យឈ្មោះសាខាឬចំណែកនៃរដ្ឋាភិបាល<u>មួយ</u> | និតិបញ្ញត្តិ(សហសភា); និតិប្រតិបត្តិ (ប្រធានាធិបតី); តុលាការ (តុលាការទាំងអស់) |
| 14. What stops <u>one</u> branch of government from becoming too powerful? | Checks and balances; separation of powers |
| 14. តើអ្វីបញ្ឈប់សាខា<u>មួយ</u>នៃរដ្ឋាភិបាលកុំឲ្យមានអំណាចខ្លាំងពេក? | ការត្រួតពិនិត្យនិងតុល្យភាព; ការបែងចែកអំណាច |
| 15. Who is in charge of the executive branch? | The President |
| 15. តើអ្នកណាទទួលខុសត្រូវសាខានិតិប្រតិបត្តិ? | ប្រធានាធិបតី |
| 16. Who makes federal laws? | Congress; Senate and House (of Representatives); (U.S. or national) legislature |
| 16. អ្នកណាបង្កើតច្បាប់សហព័ន្ធ? | សហសភា; ព្រឹទ្ធសភានិងសភា (តំណាងរាស្ត្រ); (សហរដ្ឋអាមេរិកឬជាតិ) និតិបញ្ញត្តិ |
| 17. What are the <u>two</u> parts of the U.S. Congress? | The Senate and House (of Representatives) |
| 17. តើអ្វីខ្លះជាចំណែកទាំង<u>ពីរ</u> នៃសហសភាសហរដ្ឋអាមេរិក? | ព្រឹទ្ធសភានិងសភា (តំណាងរាស្ត្រ) |
| 18. How many U.S. Senators are there? | One hundred (100) |
| 18. តើមានសមាជិកព្រឹទ្ធសភានៃសហរដ្ឋអាមេរិកចំនួនប៉ុន្មាន? | មួយរយ (100) |
| 19. We elect a U.S. Senator for how many years? | six (6) |
| 19. យើងជ្រើសតាំងសមាជិកព្រឹតតសភាចំនួនប៉ុន្មានឆ្នាំ? | ប្រាំមួយ (6) |



**បានបង្កើតឡើងដោយ Seattle Public Library ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ King County Library System និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល**
**(City of Seattle New Citizen Initiative)**

| សំណួរ | ចម្លើយ |
|---|---|
| 20. Who is <u>one</u> of your state's U.S. Senators? | *(Answers will vary.)* Patty Murray; Maria Cantwell, Washington state - 2009 |
| 20. តើជនណាម្នាក់ជាសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក នៃរដ្ឋរបស់អ្នក? | *(ចម្លើយនឹងមានការផ្លាស់ប្តូរ)* Patty Murray; Maria Cantwell, រដ្ឋវ៉ាស៊ិនតោន - ឆ្នាំ 2009 |
| 21. The House of Representatives has how many voting members? | Four hundred thirty-five (435) |
| 21. សភាតំណាងរាស្ត្រមានចំនួនសមាជិកបោះឆ្នោតប៉ុន្មាននាក់? | បួនរយសាមសិបប្រាំ (435) |
| 22. We elect a U.S. Representative for how many years? | Two (2) |
| 22. យើងជ្រើសតាំងតំណាងរាស្ត្រសហរដ្ឋអាមេរិកសំរាប់រយៈពេលប៉ុន្មានឆ្នាំ? | ពីរ (2) |
| 23. Name your U.S. Representative. | Answers will vary. For information on finding your elected official, you may go to www.house.gov/zip/ZIP2Rep.html or you may ask your local librarian. |
| 23. ចូរប្រាប់ឈ្មោះតំណាងរាស្ត្រសហរដ្ឋអាមេរិករបស់អ្នក។ | ចម្លើយនឹងមានការផ្លាស់ប្តូរ។ សំរាប់ព័ត៌មានច្រើនថែមទៀត ចំពោះការរកមន្ត្រីអ្នកជាប់ឆ្នោតរបស់អ្នក អ្នកអាចទៅមើលវិបសៃ www.house.gov/zip/ZIP2Rep.html ឬអ្នកអាចសួរនៅបណ្ណាល័យនៅក្នុងមូលដ្ឋានរបស់អ្នក។ |
| 24. Who does a U.S. Senator represent? | All people of that state |
| 24. តើសមាជិកព្រឹទ្ធសភានៃសហរដ្ឋអាមេរិកតំណាងអ្វី? | គ្រប់ប្រជាជននៅក្នុងរដ្ឋ |
| 25. Why do some states have more Representatives than other states? | (Because of) the state's population; (because) they have more people; (because) some states have more people |
| 25. ហេតុដូចម្តេចបានជារដ្ឋខ្លះមានតំណាងរាស្ត្រច្រើនជាងរដ្ឋដទៃ? | (ពីព្រោះតែ) ប្រជាជននៅក្នុងរដ្ឋ; (ពីព្រោះ) គេមានប្រជាជន ច្រើន; (ពីព្រោះ) រដ្ឋខ្លះមានប្រជាជនច្រើនជាង |
| 26. We elect a President for how many years? | Four (4) |
| 26. យើងជ្រើសតាំងប្រធានាធិបតីសំរាប់រយៈពេលប៉ុន្មានឆ្នាំ? | បួន (4) |
| 27. In what month do we vote for President? | November |
| 27. តើយើងបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅក្នុងខែណា? | ខែវិច្ឆិកា |
| 28. What is the name of the President of the United States now? | Barack Obama; Obama (2009) |
| 28. តើប្រធានាធិបតីនៃសហរដ្ឋអាមេរិកពេលឥឡូវនេះ ឈ្មោះអ្វី? | ឈ្មោះ Barack Obama; Obama (2009) |
| 29. What is the name of the Vice President of the United States now? | Joseph R. Biden, Jr.; Joe Biden; Biden |
| 29. តើអនុប្រធានាធិបតីនៃសហរដ្ឋអាមេរិកពេលឥឡូវនេះ ឈ្មោះអ្វី? | ឈ្មោះ Joseph R. Biden, Jr.; Joe Biden; Biden |
| 30. If the President can no longer serve, who becomes President? | The Vice President |
| 30. បើប្រធានាធិបតីឈប់បំរើមុខងារតទៅទៀត តើអ្នកណានឹងធ្វើជា ប្រធានាធិបតី? | អនុប្រធានាធិបតី |
| 31. If both the President and the Vice President can no longer serve, who becomes President? | The Speaker of the House |
| 31. បើទាំងប្រធានាធិបតីនិងអនុប្រធានាធិបតីមិនអាចបំរើមុខងារតទៅទៀត តើអ្នកណានឹងធ្វើជាប្រធានាធិបតី? | ប្រធានសភាតំណាងរាស្ត្រ |
| 32. Who is the Commander in Chief of the military? | The President |
| 32. តើអ្នកណាជាអគ្គមេបញ្ជាការនៃកងទ័ពជាតិ? | ប្រធានាធិបតី |
| 33. Who signs bills to become laws? | The President |
| 33. តើអ្នកណាចុះហត្ថលេខាលើសេចក្តីព្រាងច្បាប់ដើម្បីទៅជាច្បាប់? | ប្រធានាធិបតី |
| 34. Who vetoes bills? | The President |
| 34. តើអ្នកណាធ្វើវេតូសេចក្តីព្រាងច្បាប់? | ប្រធានាធិបតី |
| 35. What does the President's Cabinet do? | Advise the President |
| 35. តើគណៈរដ្ឋមន្ត្រីនៃប្រធានាធិបតីធ្វើអ្វី? | ផ្តល់ឱវាទដល់ប្រធានាធិបតី |
| 36. What are <u>two</u> Cabinet-level positions? | Secretary of Agriculture; Secretary of Commerce; Secretary of Defense; Secretary of Education; Secretary of Energy; Secretary of Health and Human Services; Secretary of Homeland Security; Secretary of Housing and Urban Development; Secretary of Interior; Secretary of State; Secretary of Transportation; Secretary of Treasury; Secretary of Veterans' Affairs; Secretary of Labor; Attorney General |
| 36. តើកិរិតមុខងារ<u>ពីរ</u>របស់គណៈរដ្ឋមន្ត្រីមានឈ្មោះអ្វី? | រដ្ឋលេខាធិការក្រសួងកសិកម្ម; រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច; រដ្ឋលេខាធិការក្រសួងការពារជាតិ; រដ្ឋលេខាធិការក្រសួងអប់រំ; រដ្ឋលេខាធិការក្រសួងថាមពល; រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមនុស្សជាតិ; រដ្ឋលេខាធិការក្រសួងសន្តិសុខនគរ; រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍គេហដ្ឋាននិងទីក្រុង; រដ្ឋលេខាធិការក្រសួង មហាផ្ទៃ; អគ្គលេខាធិការរដ្ឋ; រដ្ឋលេខាធិការក្រសួងគមនាគម; រដ្ឋលេខាធិការក្រសួងរតនាគារ; រដ្ឋលេខាធិការក្រសួងកិច្ចការ អតិតយុទ្ធជន; រដ្ឋលេខាធិការក្រសួងការងារ; អគ្គមេធាវី អនុប្រធានាធិបតី |

| សំណួរ | ចម្លើយ |
|---|---|
| 37. What does the judicial branch do? | Reviews laws; explains laws; resolves disputes (disagreements); decides if a law goes against the Constitution |
| 37. តើផ្នែកសាខាតុលាការធ្វើអ្វីខ្លះ? | ពិនិត្យច្បាប់ឡើងវិញ។ ពន្យល់ច្បាប់។ ដោះស្រាយជម្លោះ (ភាពមិនចុះសម្រុងនឹងគ្នា)។ វិនិច្ឆ័យសេចក្តី បើច្បាប់ចែងផ្ទុយ នឹងរដ្ឋធម្មនុញ្ញ |
| 38. What is the highest court in the United States? | The Supreme Court |
| 38. តើអ្វីហៅថាតុលាការជាន់ខ្ពស់ក្នុងសហរដ្ឋអាមេរិក? | តុលាការកំពូល |
| 39. How many justices are on the Supreme Court? | Nine (9) |
| 39. តើក្រុមប្រឹក្សាតុលាការមានប៉ុន្មាននាក់នៅក្នុងតុលាការកំពូល? | ប្រាំបួន (9) |
| 40. Who is the Chief Justice of the United States? | John Roberts (John G. Roberts Jr.) (2009) |
| 40. តើអ្នកណាជាប្រធាននៃក្រុមប្រឹក្សាតុលាការនៃតុលាការកំពូល? | John Roberts (John G. Roberts Jr.) (2009) |
| 41. Under our Constitution, some powers belong to the federal government. What is <u>one</u> power of the federal government? | To print money; to declare war; to create an army; to make treaties |
| 41. នៅក្រោមរដ្ឋធម្មនុញ្ញរបស់យើង អំណាចខ្លះជារបស់រដ្ឋាភិបាលសហព័ន្ធ។ តើអំណាច<u>មួយ</u>នៃរដ្ឋាភិបាលសហព័ន្ធជាអ្វី? | បោះពុម្ពប្រាក់; ប្រកាសសង្គ្រាម; បង្កើតកងទ័ព; បង្កើតកិច្ចព្រមព្រៀង |
| 42. Under our Constitution, some powers belong to the states. What is <u>one</u> power of the states? | Provide schooling and education; provide protection (police); provide safety (fire departments); give a driver's license; approve zoning and land use |
| 42. នៅក្រោមរដ្ឋធម្មនុញ្ញរបស់យើង អំណាចខ្លះជារបស់រដ្ឋ។ តើអំណាច<u>មួយ</u>របស់រដ្ឋជាអ្វី? | ផ្តល់ការសិក្សានិងការអប់រំ; ផ្តល់ការការពារ (ប៉ូលិស); ផ្តល់ សុវត្ថិភាព (ក្រសួងអគ្គីភ័យ); ផ្តល់ប័ណ្ណបើកបររថយន្ត; យល់ព្រមការប្រើប្រាស់តំបន់និងដី |
| 43. Who is the Governor of your state? | *Answers will vary*. Christine Gregoire (Washington state - 2009) |
| 43. តើនរណាជាប្រធានរដ្ឋនៅរដ្ឋរបស់អ្នក? | *ចម្លើយនឹងមានការផ្លាស់ប្តូរ។* លោកស្រី Christine Gregoire (រដ្ឋវ៉ាស៊ិនតោន - ឆ្នាំ 2009) |
| 44. What is the capital of your state? | Olympia (Washington state) |
| 44. តើរដ្ឋធានីរដ្ឋរបស់អ្នកឈ្មោះអ្វី? | Olympia (រដ្ឋវ៉ាស៊ិនតោន) |
| 45. What are the <u>two</u> major political parties in the United States? | Democratic and Republican |
| 45. . តើគណបក្សនយោបាយធំជាងគេ<u>ពីរ</u>នៅក្នុងសហរដ្ឋអាមេរិកឈ្មោះអ្វី? | ប្រជាធិបតេយ្យ និងសាធារណៈរដ្ឋ |
| 46. What is the political party of the President now? | Democratic (Party) |
| 46. តើប្រធានាធិបតីសព្វថ្ងៃនេះ នៅក្នុងគណៈបក្សនយោបាយ ណា? | (គណបក្ស) ប្រជាធិបតេយ្យ (Democratic) |
| 47. What is the name of the Speaker of the House of Representatives now? | John Boehner |
| 47. តើប្រធានសភាតំណាងរាស្ត្រឥឡូវនេះឈ្មោះអ្វី? | John Boehner |
| **Rights and Responsibilities** | |
| **សិទ្ធិនិងការទទួលខុសត្រូវ** | |
| 48. There are four amendments to the Constitution about who can vote. Describe <u>one</u> of them. | Citizens 18 and older can vote; you don't have to pay (a poll tax) to vote; a male citizen of any race can vote; any citizen (women and men) can vote |
| 48. គឺមានវិសោធនកម្មបួននៃរដ្ឋធម្មនុញ្ញអំពីជនណាដែលអាចបោះឆ្នោតបាន។ ចូរពណ៌នា<u>មួយ</u>ក្នុងចំណោមទាំងអស់។ | ពលរដ្ឋដែលមានអាយុ 18 នឹងចាស់ជាងអាចបោះឆ្នោត; អ្នកមិនចាំបាច់បង់ប្រាក់ (ពន្ធសំរាប់សន្លឹកឆ្នោត) ដើម្បីបោះឆ្នោតទេ; ពលរដ្ឋភេទប្រុសនៃគ្រប់ជាតិសាសន៍អាចបោះឆ្នោត; ពលរដ្ឋណាម្នាក់ (ស្ត្រីនឹងបុរស) អាចបោះឆ្នោត |
| 49. What is <u>one</u> responsibility that is only for U.S. citizens? | Serve on a jury; vote in a federal election |
| 49. តើការទទួលខុសត្រូវអ្វី<u>មួយ</u>ដែលពលរដ្ឋសហរដ្ឋ ទាំងអស់ត្រូវតែទទួលខុសត្រូវ? | បំរើក្នុងនាមជាក្រុមប្រឹក្សាតុលាការ។ ទៅបោះឆ្នោតនៅក្នុងការជ្រើសរើសរបស់សហព័ន្ធ |
| 50. Name <u>one</u> right only for United States citizens? | Vote in a federal election; run for federal office |
| 50. ចូរឲ្យឈ្មោះសិទ្ធិតែ<u>មួយ</u>សំរាប់ពលរដ្ឋសហរដ្ឋអាមេរិក? | ទៅបោះឆ្នោតនៅក្នុងការ ជ្រើសរើសរបស់សហព័ន្ធ។ ឈរឈ្មោះសំរាប់ការិយាល័យសហព័ន្ធ |
| 51. What are <u>two</u> rights of everyone living in the United States? | Freedom of expression; freedom of speech; freedom of assembly; freedom to petition the government; freedom of worship; the right to bear arms |
| 51. តើសិទ្ធិ<u>ពីរ</u>យ៉ាងអ្វីសំរាប់ជនម្នាក់ៗរស់នៅក្នុងសហរដ្ឋអាមេរិក? | សេរីភាពក្នុងការបញ្ចេញមតិ; សេរីភាពក្នុងការនិយាយ; សេរីភាព ក្នុងការប្រជុំ; សេរីភាពក្នុងការប្តឹងទាមទាររដ្ឋាភិបាល; សេរីភាពនៃ ជំនឿ; សេរីភាពក្នុងការមានអាវុធ |
| 52. What do we show loyalty to when we say the Pledge of Allegiance? | The United States; the flag |
| 52. តើយើងបង្ហាញសេចក្តីស្មោះត្រង់ទៅអ្វី នៅពេលដែលយើងថ្លែងសច្ចា ប្រណិធាន? | សហរដ្ឋអាមេរិក; ទង់ជាតិ |



**បានបង្កើតឡើងដោយ Seattle Public Library ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ King County Library System និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល**
**(City of Seattle New Citizen Initiative)**

| សំណួរ | ចម្លើយ |
|---|---|
| 53. What is <u>one</u> promise you make when you become a United States citizen? | Give up loyalty to other countries; defend the Constitution and laws of the United States; obey the laws of the United States; serve in the U.S. military (if needed); serve (do important work for) the nation (if needed); be loyal to the United States |
| 53. តើកិច្ចសន្យាអ្វីមួយដែលអ្នកធ្វើ នៅពេលដែលអ្នកទៅជាពលរដ្ឋសញ្ជាតិសហរដ្ឋអាមេរិក? | ឈប់ស្មោះត្រង់ទៅប្រទេសផ្សេងទៀត; ការពាររដ្ឋធម្មនុញ្ញនិងច្បាប់នៃសហរដ្ឋអាមេរិក; គោរពតាមច្បាប់នៃសហរដ្ឋអាមេរិក; បំរើនៅក្នុងកងទ័ពសហរដ្ឋអាមេរិក (បើរដ្ឋត្រូវការ); បំរើ (ធ្វើការយ៉ាងសំខាន់សំរាប់) ជាតិ (បើរដ្ឋត្រូវការ); ត្រូវស្មោះត្រង់ចំពោះសហរដ្ឋអាមេរិក |
| 54. How old do citizens have to be to vote for President? | Eighteen (18) and older |
| 54. តើអាយុប៉ុន្មានដែលពលរដ្ឋត្រូវទៅបោះឆ្នោតជ្រើសរើសប្រធានាធិបតី? | ដប់ប្រាំបី (18) និងចាស់ជាង |
| 55. What are <u>two</u> ways that Americans can participate in their democracy? | Vote; join a political party; help with a campaign; join a civic or community group; give an elected official your opinion on an issue; call Senators and Representatives; publicly support or oppose anissue or policy; run for office; write to a newspaper |
| 55. តើរបៀប<u>ពីរ</u>យ៉ាងអ្វី ដែលជនអាមេរិកាំងអាចចូលរួមនៅក្នុងភាពប្រជាធិបតេយ្យរបស់ពួកគេ? | បោះឆ្នោត; ចូលរួមគណបក្សនយោបាយ; ជួយឃោសនាបោះឆ្នោត; ចូលរួមផ្នែកលោកនិតិ ឬក្រុមសហគមន៍ ; ផ្តល់យោបល់របស់អ្នកលើបញ្ហាមួយ ទៅមន្ត្រីដែលបានគេជ្រើសតាំង; ទូរស័ព្ទទៅព្រឹទ្ធសភានឹងតំណាងរាស្ត្រ; គាំទ្រជាសាធារណៈឬជំទាស់និងបញ្ហាឬនយោបាយមួយ; ឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសរើស; សរសេរកាសែត |
| 56. When is the last day you can send in federal income tax forms? | April 15 |
| 56. តើពេលណាជាថ្ងៃចុងក្រោយបង្អស់ដែលអ្នកអាចផ្ញើក្រដាសរៀបចំពន្ធដារនៃបាក់ចំណូលសំរាប់សហព័ន្ធ? | ទី 15 ខែមេសា |
| 57. When must all men register for the Selective Service? | At age 18; between the ages of 18 and 26 |
| 57. នៅពេលណាដែលគ្រប់មនុស្សប្រុសទាំងអស់ត្រូវតែចុះឈ្មោះសំរាប់បំរើនៅក្នុងកងទ័ព? | នៅពេលមានអាយុ 18; អាយុចន្លោះរវាង 18 និង 26 |
| **AMERICAN HISTORY QUESTIONS** | |
| **សំណួរពីប្រវត្តិសាស្ត្រអាមេរិកាំង** | |
| **Colonial Period and Independence** | |
| **រយៈពេលនៃអាណានិគម និងឯករាជ្យ** | |
| 58. What is <u>one</u> reason colonists came to America? | Freedom; political liberty; religious freedom; economic opportunity; practice their religion; escape persecution |
| 58. តីមូលហេតុ<u>អ្វីមួយ</u>ដែលអាណានិគមទាំងអស់បានទៅជាប្រទេសអាមេរិក? | សេរីភាព; សេរីភាពនយោបាយ; សេរីភាពសាសនា; ឱកាសធ្វើ សេដ្ឋកិច្ច; គោរពសាសនារបស់ពួកគេ; រួចផុតពីការធ្វើទុក្ខបុកម្នេញ |
| 59. Who lived in America before the Europeans arrived? | Native Americans; American Indians |
| 59. តើអ្នកណាបានរស់នៅក្នុងអាមេរិក នៅមុនពេលដែលពួកអឺរ៉ុបបានមកដល់? | ជនជាតិដើមអាមេរិកាំង; អាមេរិកាំងឥណ្ឌាន |
| 60. What group of people was taken to America and sold as slaves? | Africans; people from Africa |
| 60. តើក្រុមប្រជាជនណាត្រូវបានគេយកមកអាមេរិក និងបានលក់ជាទាសករ? | ជនជាតិអាហ្វ្រិកាំង; ប្រជាជនមកពីអាហ្វ្រិកា |
| 61. Why did the colonists fight the British? | Because of high taxes (taxation without representation); because the British army stayed in their houses (boarding, quartering); because they didn't have self-government |
| 61. ហេតុដូចម្តេចបានជាអាណានិគមទាំងអស់ច្បាំងជាមួយពួកអង់គ្លេស? | ពីព្រោះបង់ពន្ធខ្ពស់ (បង់ពន្ធដោយគ្មានការដាក់តាំងឲ្យឃើញជាក់); ពីព្រោះកងទ័ពអង់គ្លេសបានរស់នៅក្នុងផ្ទះរបស់ពួកគេ (ការផ្តល់ អាហារ, ការយកកន្លែងនៅ); ពីព្រោះពួកគេមិនមានរដ្ឋាភិបាល ផ្ទាល់ខ្លួនរបស់គេ |
| 62. Who wrote the Declaration of Independence? | (Thomas) Jefferson |
| 62. អ្នកណាជាអ្នកសរសេរសេចក្តីប្រកាសនៃឯករាជ្យ? | (Thomas) Jefferson |
| 63. When was the Declaration of Independence adopted? | July 4, 1776 |
| 63. នៅពេលណាសេចក្តីប្រកាសនៃឯករាជ្យត្រូវបានយល់ព្រម? | ថ្ងៃទី 4 ខែកក្កដាឆ្នាំ 1776 |
| 64. There were 13 original states. Name <u>three</u>. | New Hampshire; Massachusetts; Rhode Island; Connecticut; New York; New Jersey; Pennsylvania; Delaware; Maryland; Virginia; North Carolina; South Carolina; Georgia |
| 64. គឺមានរដ្ឋដំបូងចំនួន 13 ។ ចូរឲ្យឈ្មោះ <u>បី</u> ។ | New Hampshire; Massachusetts; Rhode Island; Connecticut; New York; New Jersey; Pennsylvania; Delaware; Maryland; Virginia; North Carolina; South Carolina; Georgia |



បានបង្កើតឡើងដោយ **Seattle Public Library** ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ **King County Library System** និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល

**(City of Seattle New Citizen Initiative)**

| សំណួរ | ចម្លើយ |
|---|---|
| 65. What happened at the Constitutional Convention? | The Constitution was written; the Founding Fathers wrote the Constitution |
| 65. តើមានអ្វីកើតឡើងនៅពេលសន្និសីទរដ្ឋធម្មនុញ្ញ? | រដ្ឋធម្មនុញ្ញត្រូវបានគេសរសេរឡើង; ក្រុមបិតាដែលបានបង្កើតជាតិបានសរសេររដ្ឋធម្មនុញ្ញ |
| 66. When was the Constitution written? | 1787 |
| 66. នៅពេលណាដែលរដ្ឋធម្មនុញ្ញបានសរសេរឡើង? | ឆ្នាំ 1787 |
| 67. The Federalist Papers supported the passage of the U.S. Constitution. Name one of the writers. | (James) Madison; (Alexander) Hamilton; (John) Jay; Publius |
| 67. អត្ថបទ (The Federalist Papers) បានគាំទ្រអត្ថបទសេចក្តីនៅក្នុងរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក។ ចូរឲ្យឈ្មោះម្នាក់នៃអ្នកសរសេរអត្ថបទនេះ។ | ឈ្មោះអ្នកសរសេរ (James) Madison; (Alexander) Hamilton; (John) Jay; Publius |
| 68. What is one thing Benjamin Franklin is famous for? | U.S. diplomat; oldest member of the Constitutional Convention; first Postmaster General of the United States; writer of "Poor Richard's Almanac"; started the first free libraries |
| 68. តើអ្វីមួយដែលធ្វើឲ្យលោក Benjamin Franklin មានការល្បីល្បាញ? | រដ្ឋទូតនៃសហរដ្ឋអាមេរិក; សមាជិកចាស់ជាងគេបង្អស់នៃការសន្និសីទ រដ្ឋធម្មនុញ្ញ; អ្នកធ្វើការប៉ុស្តិ៍សំបុត្រទូទៅទីមួយនៃសហរដ្ឋអាមេរិក; អ្នកសរសេររឿងមហាសង្គ្រាន "Poor Richard's Almanac"; បានចាប់ផ្តើមបណ្ណាល័យសេរីទីមួយ |
| 69. Who is the "Father of Our Country"? | (George) Washington |
| 69. អ្នកណាជា "បិតារបស់ប្រទេសយើង"? | (George) Washington (ជចវ៉ាស៊ិនតោន) |
| 70. Who was the first President? | (George) Washington |
| 70. អ្នកណាជាប្រធានាធិបតីទីមួយ? | (George) Washington (ជចវ៉ាស៊ិនតោន) |
| **1800s** | |
| កំឡុងឆ្នាំ **1800** | |
| 71. What territory did the U.S. buy from France in 1803? | The Louisiana Territory; Louisiana |
| 71. តើទឹកដីត្រួតត្រាណាដែលសហរដ្ឋអាមេរិកបានទិញពីបារាំងក្នុងឆ្នាំ 1803? | ទឹកដីត្រួតត្រានៃ Louisiana; រដ្ឋ Louisiana |
| 72. Name one war fought by the United States in the 1800s. | War of 1812; Mexican-American War; Civil War; Spanish-American War |
| 72. ចូរឲ្យឈ្មោះសង្គ្រាមមួយ ដែលសហរដ្ឋអាមេរិកបានច្បាំងកំឡុងឆ្នាំ 1800? | សង្គ្រាមឆ្នាំ 1812; សង្គ្រាមអាមេរិកាំង-មិចស៊ិក; សង្គ្រាមស៊ីវិល; សង្គ្រាមអាមេរិកាំង-អេស្ប៉ាញញ៉ុល |
| 73. Name the U.S. war between the North and the South. | The Civil War; the War between the States |
| 73. ចូរឲ្យឈ្មោះសង្គ្រាមសហរដ្ឋអាមេរិករវាងពួកខាងជើងនឹងខាងត្បូង។ | សង្គ្រាមស៊ីវិល; សង្គ្រាមរវាងរដ្ឋនានា |
| 74. Name one problem that led to the Civil War. | Slavery; economic reasons; states' rights |
| 74. ចូរឲ្យឈ្មោះបញ្ហាមួយដែលបាននាំឲ្យមានសង្គ្រាមស៊ីវិល។ | ទាសកម្ម; មូលហេតុសេដ្ឋកិច្ច; សិទ្ធិរបស់រដ្ឋ |
| 75. What was one important thing that Abraham Lincoln did? | Freed the slaves (Emancipation Proclamation); saved (or preserved) the Union; led the United States during the Civil War |
| 75. តើវត្ថុសំខាន់អ្វីមួយដែលលោក Abraham Lincoln បានធ្វើ? | បានដោះលែងទាសករ (សេចក្តីប្រកាសដោះលែង); សង្គ្រោះ (ឬបានរក្សាទុក) សហភាព; បានដឹកនាំសហរដ្ឋអាមេរិកនៅពេល សង្គ្រាមស៊ីវិល |
| 76. What did the Emencipation Proclamation do? | Freed the slaves; freed slaves in the Confederacy; freed slaves in the Confederate states; freed slaves in most Southern states |
| 76. តើសេចក្តីប្រកាសដោះលែងបានធ្វើអ្វីខ្លះ? | បានដោះលែងទាសករ; បានដោះលែងទាសករនៅក្នុងសហព័ន្ធ; បានដោះលែងទាសករនៅក្នុងរដ្ឋសហព័ន្ធ; បានដោះលែងទាសករនៅស្ទើរតែគ្រប់រដ្ឋផ្នែកខាងត្បូង |
| 77. What did Susan B. Anthony do? | Fought for women's rights; fought for civil rights |
| 77. តើលោកស្រី Susan B. Anthony បានធ្វើអ្វី? | បានទាមទារសិទ្ធិសំរាប់ស្ត្រីទាំងអស់; បានទាមទារសិទ្ធិមនុស្ស |
| **Recent American History and Other Important Historical Information** | |
| **ប្រវត្តិសាស្ត្រអាមេរិកាំងពេលថ្មីៗ និងព័ត៌មាននៃប្រវត្តិសាស្ត្រសំខាន់ៗដទៃផ្សេងទៀត** | |
| 78. Name one war fought by the United States in the 1900s. | World War I; World War II; Korean War; Vietnam War; (Persian) Gulf War |
| 78. ចូរឲ្យឈ្មោះសង្គ្រាមមួយដែលសហរដ្ឋអាមេរិកបានច្បាំងកំឡុងឆ្នាំ 1900 ។ | សង្គ្រាមលោកលើកទី I; សង្គ្រាមលោកលើកទី II; សង្គ្រាមកូរេ; សង្គ្រាមវៀតណាម; សង្គ្រាមសមុទ្រហ្គូល (សមុទ្រពែក្ស) |
| 79. Who was President during World War I? | (Woodrow) Wilson |
| 79. តើអ្នកណាជាប្រធានាធិបតីនៅពេលសង្គ្រាមលោកលើកទី I? | (Woodrow) Wilson |
| 80. Who was President during the Great Depression and World War II? | (Franklin) Roosevelt |
| 80. តើអ្នកណាជាប្រធានាធិបតីនៅពេលសេដ្ឋកិច្ចធ្លាក់ដុនដាប និងពេលសង្គ្រាមលោកលើកទី II? | (Franklin) Roosevelt |



បានបង្កើតឡើងដោយ **Seattle Public Library** ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ **King County Library System** និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល

**(City of Seattle New Citizen Initiative)**

| សំណួរ | ចម្លើយ |
|---|---|
| 81. Who did the United States fight in World War II? | Japan, Germany, and Italy |
| 81. តើប្រទេសណាដែលសហរដ្ឋអាមេរិកច្បាំងជាមួយនៅពេលសង្គ្រាម លោកលើកទី II? | ជប៉ុន, អាឡឺម៉ង់, និងអ៊ីតាលី |
| 82. Before he was President, Eisenhower was a general. What war was he in? | World War II |
| 82. មុនពេលគាត់បានជាប់ជាប្រធានាធិបតី លោក Eisenhower ជាឧត្តមសេនីយម្នាក់។ តើគាត់បានទៅច្បាំងក្នុងសង្គ្រាមណា? | សង្គ្រាមលោកលើកទី II |
| 83. During the Cold War, what was the main concern of the United States? | Communism |
| 83. នៅពេលសង្គ្រាមត្រជាក់ តើការបារម្ភអ្វីដែលធំជាងគេនៃសហរដ្ឋអាមេរិក? | កុម្មុយនិស |
| 84. What movement tried to end racial discrimination? | Civil rights (movement) |
| 84. តើចលនាអ្វីបានសាកល្បងដើម្បីបញ្ចប់ការរើសអើងប្រកាន់ពូជសាសន៍? | សិទ្ធិមនុស្ស (ចលនា) |
| 85. What did Martin Luther King Jr. do? | Fought for civil rights; worked for equality for all Americans |
| 85. តើលោក Martin Luther King Jr. បានធ្វើអ្វី? | ទាមទារសិទ្ធិមនុស្ស; បានធ្វើការឲ្យមានភាពស្មើៗគ្នាទាំងអស់ គ្រប់ជនអាមេរិកាំង |
| 86. What major event happened on September 11, 2001 in the United States? | Terrorists attacked the United States |
| 86. តើព្រឹត្តិការណ៍អ្វីដែលសំខាន់ជាងគេ បានកើតឡើងនៅថ្ងៃទី 11 ខែកញ្ញាឆ្នាំ 2001 នៅសហរដ្ឋអាមេរិក? | ភេរវជនបានវាយប្រហារសហរដ្ឋអាមេរិក |
| 87. Name one American Indian tribe in the United States. ( USCIS officer will be supplied with a list of federally recognized American Indian tribes) | Cherokee; Navajo; Sioux; Chippewa; Choctaw; Pueblo; Apache; Iroquois; Creek; Blackfeet; Seminole; Cheyenne; Arawak; Shawnee; Mohegan; Huron; Oneida; Lakota; Crow; Teton; Hopi; Inuit |
| 87. ចូរឲ្យឈ្មោះ កុលសម្ព័ន្ធឥណ្ឌានអាមេរិកាំងម្នាក់នៅក្នុង សហរដ្ឋអាមេរិក។ (មន្ត្រី USCIS នឹងត្រូវគេផ្តល់ជូន នូវបញ្ជីកុលសម្ព័ន្ធឥណ្ឌានអាមេរិកាំង ដែលបានទទួលស្គាល់ដោយសហព័ន្ធ) | ឈ្មោះកុលសម្ព័ន្ធ Cherokee; Navajo; Sioux; Chippewa; Choctaw; Pueblo; Apache; Iroquois; Creek; Blackfeet; Seminole; Cheyenne; Arawak; Shawnee; Mohegan; Huron; Oneida; Lakota; Crow; Teton; Hopi; Inuit |
| **INTEGRATED CIVICS QUESTIONS** | |
| **សំណួរលោកនិតិបញ្ញត្តិគ្នាទាំងអស់** | |
| **Geography** | |
| **ភូមិសាស្ត្រ** | |
| 88. Name one of the two longest rivers in the United States. | Missouri (River); Mississippi (River) |
| 88. ចូរឲ្យឈ្មោះមួយ នៃស្ទឹងដែលវែងជាងគេពីរនៅក្នុងសហរដ្ឋអាមេរិក? | Missouri ( ស្ទឹង); Mississippi ( ស្ទឹង) |
| 89. What ocean is on the West Coast of the United States? | Pacific (Ocean) |
| 89. តើមហាសមុទ្រណាជាប់នៅឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក? | ប៉ាស៊ីហ្វិក (មហាសមុទ្រ) |
| 90. What ocean is on the East Coast of the United States? | Atlantic (Ocean) |
| 90. តើមហាសមុទ្រណាជាប់នៅឆ្នេរខាងកើតនៃសហរដ្ឋអាមេរិក? | អាត្លង់ទិក (មហាសមុទ្រ) |
| 91. Name one U.S. territory. | Puerto Rico; U.S. Virgin Islands; American Samoa; Northern Mariana Islands; Guam |
| 91. ចូរឲ្យឈ្មោះមួយនៃតំបន់ត្រួតត្រាសហរដ្ឋអាមេរិក។ | Puerto Rico; U.S. កោះ Virgin Islands; American Samoa; កោះ Northern Mariana Islands; Guam |
| 92. Name one state that borders Canada. | Maine; New Hampshire; Vermont; New York; Pennsylvania; Ohio; Michigan; Minnesota; North Dakota; Montana; Idaho; Washington; Alaska |
| 92. ចូរឲ្យឈ្មោះមួយនៃរដ្ឋដែលជាប់នឹងប្រទេសកាណាដា។ | Maine; New Hampshire; Vermont; New York; Pennsylvania; Ohio; Michigan; Minnesota; North Dakota; Montana; Idaho; Washington; Alaska |
| 93. Name one state that borders Mexico. | California; Arizona; New Mexico; Texas |
| 93. ចូរឲ្យឈ្មោះមួយនៃរដ្ឋដែលជាប់នឹងប្រទេសម៉ិចស៊ិក។ | California; Arizona; New Mexico; Texas |
| 94. What is the capital of the United States? | Washington, D.C. |
| 94. តើរដ្ឋធានីសហរដ្ឋអាមេរិកឈ្មោះអ្វី? | វ៉ាស៊ីនតោន ឌីស៊ី |
| 95. Where is the Statue of Liberty? | New York (Harbor); Liberty Island [Also acceptable are New Jersey, near New York City, and on the Hudson (River).] |
| 95. តើរូបបដិមាករសេរីភាពតាំងនៅទីណា? | ក្នុងរដ្ឋ New York (Harbor); កោះសេរីភាព [ក៏ទទួលស្គាល់ទៀតថានៅក្នុងរដ្ឋ New Jersey, នៅក្បែរទីក្រុង New York, ហើយនិងនៅតាម Hudson (ស្ទឹង).] |
| **Symbols** | |
| **និមិត្តរូប** | |
| 96. Why does the flag have 13 stripes? | Because there were 13 original colonies; because the stripes represent the original colonies |
| 96. ហេតុដូចម្តេចបានជាទង់ជាតិមានឆ្នូត 13? | ពីព្រោះមានរដ្ឋអាណានិគមដំបូង 13; ពីព្រោះឆ្នូតទាំងអស់ បានតំណាងឲ្យរដ្ឋអាណានិគមដំបូង |

| សំណួរ | ចម្លើយ |
|---|---|
| 97. Why does the flag have 50 stars? | Because there is one star for each state; because each star represents a state; because there are 50 states |
| 97. ហេតុដូចម្តេចបានជាទង់ជាតិមានផ្កាយ 50? | ពីព្រោះមានរដ្ឋមួយសំរាប់រដ្ឋនិមួយៗ; ពីព្រោះផ្កាយមួយ តំណាងរដ្ឋមួយ; ពីព្រោះមានរដ្ឋ 50 |
| 98. What is the name of the national anthem? | The Star-Spangled Banner |
| 98. តើភ្លេងជាតិហៅថាឈ្មោះអ្វី? | The Star-Spangled Banner (បទភ្លេងជាតិ Star-Spangled Banner) |
| **Holidays** | |
| **ថ្ងៃបុណ្យទាំងអស់** | |
| 99. When do we celebrate Independence Day? | July 4 |
| 99. តើនៅពេលណាយើងធ្វើពិធីបុណ្យថ្ងៃឯករាជ្យ? | ថ្ងៃទី 4 ខែកក្កដា |
| 100. Name <u>two</u> national U.S. holidays. | New Year's Day; Martin Luther King Jr. Day; Presidents Day; Memorial Day; Independence Day; Labor Day; Columbus Day; Veterans Day; Thanksgiving; Christmas |
| 100. ចូរឲ្យឈ្មោះបុណ្យជាតិនៃសហរដ្ឋអាមេរិក<u>ពីរ</u>។ | ថ្ងៃបុណ្យចូលឆ្នាំ; ថ្ងៃបុណ្យលោក Martin Luther King Jr.; ថ្ងៃបុណ្យប្រធានាធិបតី; ថ្ងៃបុណ្យរំលឹកវិញ្ញាណខ័ន្ធ; ថ្ងៃបុណ្យ ឯករាជ្យ; ថ្ងៃបុណ្យការងារ; ថ្ងៃបុណ្យ Columbus; ថ្ងៃបុណ្យ អតីតយុទ្ធជន; ថ្ងៃបុណ្យអំណរគុណព្រះ; ថ្ងៃបុណ្យកំណើតព្រះយេស៊ូ |

## សំណួរសិក្សានានាសំរាប់**អ្នកដាក់ពាក្យសុំមានវ័យចំណាស់** សំរាប់ការកែប្រែថ្មីនៃមុខវិជ្ជាប្រឡង

ប្រជាជនដែលមានអាយុលើសពី 65 ដែលជាពលរដ្ឋរស់នៅជាអចិន្ត្រៃយ៏ស្របច្បាប់ (មានប័ណ្ណបៃតង) និងជាអ្នករស់នៅក្នុងសហរដ្ឋអាមេរិកជាអចិន្ត្រៃយ៏សបច្បាប់សំរាប់រយះពេលយ៉ាងតិច 20 ឆ្នាំ ត្រូវមានការត្រូវខុសគ្នា សំរាប់ចំណេះដឹងលោកនិតិ (ប្រវត្តសាស្ត្រនិងរដ្ឋាភិបាល)។ ពួកគេ ក៏អាចមានលក្ខណសម្បត្តិត្រូវគេធ្វើតេស្តជាភាសាកំណើតរបស់ពួកគេដែរ។ ចូរមើល*ជំពូក E* សំរាប់ព័ត៌មានច្រើនថែមទៀត។

| សំណួរ | ចម្លើយ |
|---|---|
| 1. What is <u>one</u> right or freedom from the First Amendment? | Speech; religion; assembly; press; petition the government |
| 1. តើសិទ្ធិឬសេរីភាព<u>មួយ</u>មកពីវិសោធនកម្មទីមួយហៅថាអ្វី? | ការនិយាយ; សាសនា; ការប្រជុំ; ការផ្សាយព័ត៌មាន; ប្តឹងសុំទាមទាររដ្ឋាភិបាល |
| 2. What is the economic system in the United States? | Capitalist economy; market economy |
| 2. តើប្រព័ន្ធសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកហៅថាអ្វី? | សេដ្ឋកិច្ចមូលធន; សេដ្ឋកិច្ចទីផ្សារ |
| 3. Name <u>one</u> branch or part of the government. | Legislative (Congress); executive (President); judicial (the courts) |
| 3. ចូរឲ្យឈ្មោះ<u>មួយ</u>នៃសាខាឬចំណែកនៃរដ្ឋាភិបាល។ | និតិបញ្ញត្តិ(សហសភា); និតិប្រតិបត្តិ (ប្រធានាធិបតី); តុលាការ (តុលាការទាំងអស់) |
| 4. What are the <u>two</u> parts of the U.S. Congress? | The Senate and House (of Representatives) |
| 4. តើអ្វីជាចំណែកទាំង<u>ពីរ</u> នៃសហសភាសហរដ្ឋអាមេរិក? | ព្រឹទ្ធសភានិងសភា (តំណាងរាស្ត្រ) |
| 5. Who is <u>one</u> of your state's U.S. Senators? | Patty Murray; Maria Cantwell (Washington state - 2009) |
| 5. តើអ្នកណាជាសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក<u>ម្នាក់</u>នៃរដ្ឋរបស់អ្នក? | Patty Murray; Maria Cantwell (រដ្ឋវ៉ាស៊ីនតោន – ឆ្នាំ 2009) |
| 6. In what month do we vote for President? | November |
| 6. តើយើងបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅក្នុងខែណា? | វិច្ឆិកា |
| 7. What is the name of the President of the U.S. now? | Barack Obama; Obama |
| 7. តើប្រធានាធិបតីនៃសហរដ្ឋអាមេរិកសព្វថ្ងៃនេះឈ្មោះអ្វី? | Barack Obama; Obama |
| 8. What is the capital of your state? | Olympia (Washington state) |
| 8. តើរដ្ឋធានីនៃរដ្ឋរបស់អ្នកឈ្មោះអ្វី? | អូឡាំព្យា (រដ្ឋវ៉ាស៊ិនតោន) |
| 9. What are the <u>two</u> major political parties in the United States? | Democratic and Republican |
| 9. តើគណបក្សនយោបាយធំពីរនៅក្នុងសហរដ្ឋអាមេរិកមានឈ្មោះអ្វីខ្លះ? | ប្រជាធិបតេយ្យ និងសាធារណៈរដ្ឋ |
| 10. What is <u>one</u> responsibility that is only for U.S. citizens? | Serve on a jury; vote |
| 10. តើការទទួលខុសត្រូវអ្វី<u>មួយ</u>ដែលជាការទទួលខុសត្រូវមួយសំរាប់ពលរដ្ឋសហរដ្ឋអាមេរិក? | បំរើក្នុងគណៈវិនិច្ឆ័យ; បោះឆ្នោត |
| 11. How old do citizens have to be to vote for President? | Eighteen (18) and older |
| 11. តើអាយុប៉ុន្មានដែលពលរដ្ឋត្រូវទៅបោះឆ្នោតជ្រើរើសប្រធានាធិបតី? | ដប់ប្រាំបី (18) និងចាស់ជាង |
| 12. When is the last day you can send in federal income tax forms? | April 15 |
| 12. តើពេលណាជាថ្ងៃចុងក្រោយបង្អស់ដែលអ្នកអាចផ្ញើក្រដាសរៀបចំពន្ធដារនៃបាក់ចំណូលសំរាប់សហព័ន្ធ? | ថ្ងៃទី 15 ខែមេសា |
| 13. Who was the first President? | (George) Washington |
| 13. អ្នកណាជាប្រធានាធិបតីទីមួយ? | (George) Washington (ជចវ៉ាស៊ីនតោន) |



បានបង្កើតឡើងដោយ **Seattle Public Library** ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ **King County Library System** និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល
**(City of Seattle New Citizen Initiative)**

| **សំណួរ** | **ចម្លើយ** |
|---|---|
| 14. What was <u>one</u> important thing that Abraham Lincoln did? | Freed the slaves (Emancipation Proclamation); saved (preserved) the Union; led U.S. during the Civil War |
| 14. តើវត្ថុសំខាន់អ្វី<u>មួយ</u>ដែលលោក Abraham Lincoln បានធ្វើ**?** | ឲ្យទាសករមានសេរីភាព (សេចក្តីប្រកាសដោះលែង); សង្គ្រោះ (ឬបានរក្សាទុក) សហភាព; បានដឹកនាំសហរដ្ឋអាមេរិកនៅពេលសង្គ្រាមស៊ីវិល |
| 15. Name <u>one</u> war fought by the United States in the 1900s. | World War I; World War II; Korean War; Vietnam War; (Persian) Gulf War |
| 15. ចូរឲ្យឈ្មោះសង្គ្រាម<u>មួយ</u>ដែលសហរដ្ឋអាមេរិកបានច្បាំងក្នុងកំឡុងឆ្នាំ 1900 ។ | សង្គ្រាមលោកលើកទី I; សង្គ្រាមលោកលើកទី II; សង្គ្រាមកូរេ; សង្គ្រាមវៀតណាម; សង្គ្រាមសមុទ្រហ្គូល (សមុទ្រពែក្ស) |
| 16. What did Martin Luther King Jr. do? | Fought for civil rights; worked for equality for all Americans |
| 16. តើលោក Martin Luther King Jr. បានធ្វើអ្វីខ្លះ**?** | ទាមទារសិទ្ធិមនុស្ស; បានធ្វើការឲ្យមានភាពស្មើៗគ្នាទាំងអស់គ្រប់ជនអាមេរិកាំង |
| 17. What is the capital of the United States? | Washington, D.C. |
| 17. តើរដ្ឋធានីនៃសហរដ្ឋអាមេរិកឈ្មោះអ្វី**?** | Washington, D.C. (វ៉ាស៊ិនតោន ឌីស៊ី) |
| 18. Where is the Statue of Liberty? | New York (Harbor); Liberty Island [Also acceptable are New Jersey, near New York City, and on the Hudson (River).] |
| 18. តើនិមិត្តរូបសេរីភាពតាំងនៅទីណា**?** | ក្នុងរដ្ឋ New York (Harbor); កោះសេរីភាព [ក៏ទទួលស្គាល់ទៀតថានៅក្នុងរដ្ឋ New Jersey, នៅក្បែរទីក្រុង New York, ហើយនិងនៅតាម Hudson (ស្ទឹង).] |
| 19. Why does the flag have 50 stars? | Because there is one star for each state; because each star represents a state; because there are 50 states |
| 19. ហេតុដូចម្តេចបានជាទង់ជាតិមានផ្កាយ 50? | ពីព្រោះមានផ្កាយមួយសំរាប់រដ្ឋមួយ; ពីព្រោះផ្កាយតំណាងឲ្យរដ្ឋមួយ; ពីព្រោះមានរដ្ឋ 50 |
| 20. When do we celebrate Independence Day? | July 4 |
| 20. តើនៅពេលណាយើងធ្វើពិធីបុណ្យថ្ងៃឯករាជ្យ**?** | ថ្ងៃទី 4 ខែកក្កដា |



**បានបង្កើតឡើងដោយ Seattle Public Library ក្នុងភាពជាដៃគូជាមួយនឹងបណ្ណាល័យ King County Library System និងមន្ទីរផ្តើមចូលសញ្ជាតិថ្មីនៃក្រុងស៊ីអាថល**

**(City of Seattle New Citizen Initiative)**